**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ និងសាធារណជន មេត្តាជ្រាបថា ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងបេឡាជាតិសន្តិសុខសង្គម សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តសៀមរាប នឹងរៀបចំ **"ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ"** នៅតាមបណ្តាខេត្តចំនួន៣ គឺថ្ងៃទី១៥-១៦ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅខេត្តបាត់ដំបង, ថ្ងៃទី២២-២៣ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅខេត្តបន្ទាយមានជ័យ និងថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅខេត្តសៀមរាប ក្នុងគោលបំណងៈ

- បង្កើតជាវេទិកាជំនួបដ៏ធំរវាងអ្នកស្វែងរកការងារ និងនិយោជក ដើម្បីដាក់ពាក្យស្វែងរកការងារ ជ្រើសរើសបុគ្គលិក សម្ភាសភ្លាម និងទទួលបានការងារភ្លាមនៅហ្នឹងកន្លែង
- បង្កើនការយល់ដឹងបន្ថែមអំពីអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម (ប.ស.ស.) សម្រាប់កម្មករនិយោជិតនៅពេលចូលបម្រើការងារនៅក្នុងស្រុក
- ផ្សព្វផ្សាយ និងចុះឈ្មោះចូលរៀនវគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ពិព័រណ៍ការងារនេះ នឹងមានសហគ្រាស ក្រុមហ៊ុន រោងចក្រ អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងសមាគមចូលរួមផ្សព្វផ្សាយ និងដាក់តាំងបង្ហាញសមិទ្ធផលវគ្គអប់រំបណ្តុះបណ្តាល និងព័ត៌មានឱកាសការងារដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្មរាប់ម៉ឺនកន្លែង ដោយមានការសម្ភាសជ្រើសរើសបុគ្គលិកដោយផ្ទាល់នៅហ្នឹងកន្លែង។

សម្រាប់អ្នកចូលរួមនឹងអាចទទួលបានការកាត់សក់ អាហារ ភេសជ្ជៈ និងអាហារូបករណ៍ ដោយឥតគិតថ្លៃផងដែរ។ សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងតាមរយៈប្រព័ន្ធ Hotline លេខ "១២៩៧" ឬលេខទូរសព្ទ ០៧៧ ២៣២ ៣៧៨ /០១៧ ៨៧១ ៨០៧។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមនិយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ និងសាធារណជន ជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥